**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ឌី&ជេ (ខេមបូឌា) ឯ.ក
# និង
# តំណាងប្រតិភូបុគ្គលិក និង សហជីពការងារកម្មករកម្ពុជា សហជីពការងារកម្មករកម្ពុជាដើម្បីសន្តិភាព សហជីពការងារកម្មករកម្ពុជាដើម្បីអភិវឌ្ឍន៍ ប្រចាំរោងចក្រ ឌី&ជេ (ខេមបូឌា) ឯ.ក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ វេលាម៉ោង ១៣និង០០នាទី នៅក្នុងរោងចក្រ ឌី&ជេ (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាង តំណាងក្រុមហ៊ុន និង តំណាងកម្មករ សហជីពការងារកម្មករកម្ពុជា សហជីពការងារកម្មករកម្ពុជាដើម្បីសន្តិភាព សហជីពការងារកម្មករកម្ពុជាដើម្បីអភិវឌ្ឍន៍ ប្រចាំរោងចក្រ។

នៅក្នុងអង្គប្រជុំនេះ តំណាងនាយកក្រុមហ៊ុនបានជូនដំណឹងដល់បងប្អូនកម្មករ កម្មការិនីទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរោងចក្រថា ដោយសារតែជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ COVID-19 ពេលនេះរោងចក្រមិនមានការបញ្ជាទិញគ្រប់គ្រាន់ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរការងាររបស់បងប្អូនបុគ្គលិកកម្មករកម្មការិនីចំនួន ១២៣នាក់ ក្នុងរយៈពេល២ខែ(ពីរខែ) គឺចាប់ពីថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០២០ ទៅដល់ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ បងប្អូនកម្មករកម្មការិនីបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនដូចខាងក្រោម៖

១-ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភក្នុង១ខែចំនួន ៣០ដុល្លារ

២-រដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភក្នុង១ខែចំនួន ៤០ដុល្លារ

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១៣និង៤៥នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃច័ន្ទ ២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ភ្នំពេញ, ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌី&ជេ (ខេមបូឌា) ឯ.ក D & J (CAMBODIA) CO.,LTD KINGDOM OF CAMBODIA

# តំណាងប្រតិភូបុគ្គលិក និង តំណាងសហជីព

១. ប៊ូ រតនា



២. ធួក ប៊ុនថេត



៣. ឆាំ ឆាវ៉ាត់



៤. ការន ម៉ាណែត



៥. សួង រិត



៦. ង៉ុប ស្រីវៀត



៧. សែម សេង



៨. ដៀប ពិសិដ្ឋ



៩. ឡាំ គុឡា



១០. ផាន់ សាវ៉ាពង្ស

